ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-May-2011, 15:10
CMS/CFO: Kauv Keoratanak

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ: សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ: សាធារណៈ/Public 04/11/2011

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង "សំណើរបស់ អៀង សារី សុំយាង និងកោះអញ្ជើញសម្តេចព្រះវររាជបិតា នរោត្តម សីហនុ, នាយករដ្ឋមន្ត្រី ហ៊ុន សែន, ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និង សម្តេច ជា ស៊ីម"

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម ធូ មណី

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន
អៀង ធីរិទ្ធ

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម

លោក Michael G.KARNAVAS
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC
លោក ស សូវ៉ាន
លោក Jacques VERGÈS

## I. សំណើ

១. នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១ អៀង សារី តាមរយៈមេធាវីការពារក្តីរបស់គាត់ ("មេធាវីការពារក្តី") បានដាក់សំណើរបស់គាត់ "សុំឃាង និងកោះអញ្ជើញសម្តេចព្រះវររាជបិតា នរោត្តម សីហនុ, នាយករដ្ឋមន្ត្រី ហ៊ុន សែន, ព្រះអង្គម្ចាស់ នរោត្តម រណប្ញទ្ធិ និងសម្តេចជា ស៊ីម"[1]("ញត្តិស្នើសុំ")។ មេធាវីការពារក្តីស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងឃាង និងកោះអញ្ជើញសាក្សីដើម្បីថ្វាយ និងផ្តល់សក្ខីកម្មនៅពេលសវនាការបឋមអំពី "សារតារ វិសាលភាព និងគោលបំណងដែលនៅពីក្រោយ" ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសរបស់ អៀង សារី ("RPA")[2] ។ ពួកគេតវ៉ាថា វិសាលភាពនៃ RPA ត្រូវបានវាយតម្លៃតែតាមរយៈភស្តុតាងចចាមអារ៉ាមតែប៉ុណ្ណោះនិងថា អាស្រ័យហេតុនេះ សក្ខីកម្មរបស់សាក្សី គួរត្រូវបានស្តាប់ដើម្បីបញ្ជាក់នូវវិសាលភាពរបស់វាឲ្យបានពេញលេញ។ ជាងនេះទៀត ពួកគេតវ៉ាថា សាក្សីទាំងនេះគួរត្រូវបានឃាង និងកោះអញ្ជើញ ដោយសារអង្គជំនុំជម្រះសាលាដំបូង មានសិទ្ធិអំណាចដើម្បីធានាដល់ការចូលបង្ហាញខ្លួននៅតុលាការនេះ ក្រោមវិធានផ្ទៃក្នុង អ.វ.ត.ក ("វិធាន") និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា("CCPC")[3] ។ដូចមូលហេតុបញ្ជាក់ជូនខាងក្រោម សហព្រះរាជអាជ្ញាសូមស្នើឲ្យបដិសេធចោលញត្តិស្នើសុំនេះ

## II. ប្រវត្តិនៃនីតិវិធី

២. បន្ទាប់ពីការដាក់ញត្តិនេះកាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១ ពីរថ្ងៃក្រោយមកទៀតគឺនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញអនុស្សារណៈរបស់ខ្លួន "កំណត់កាលបរិច្ឆេទសំរាប់បើកសវនាការបឋម" ("សេចក្តីសំរេចកំណត់កាលបរិច្ឆេទ") ដែលនៅក្នុងនោះអង្គជំនុំជម្រះបានសម្រេចថា ខ្លួននឹងពិនិត្យពិចារណាតែលើបញ្ហាដែលទាក់ទងនឹង "បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញដែលបានដាក់ដោយភាគីនានាស្របតាមវិធានផ្ទៃក្នុង", "អញ្ញត្រកម្មបឋម" និង "ការបញ្ជាក់អំពីខ្លឹមសារនៃសំណាងដែលមេធាវីនាំមុខមានបំណងទាមទារ[...]"[4] តែប៉ុណ្ណោះ ។ កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ អង្គជនុំជម្រះសាលាដំបូង បន្ទាប់មកទៀត បានចេញដីកាសម្រេចចំនួនពីរលើអញ្ញត្រកម្មបឋមបន្ថែម ដែលបានដាក់ជូនដោយមេធាវីការពារក្តីរូបនេះ ដែលដីកាសម្រេចទី១ ទាក់ទងនឹងព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសរបស់ព្រះ

---

[1] ឯកសារលេខ E85, ញត្តិស្នើសុំរបស់ អៀង សារី "សុំឃាង និង កោះអញ្ជើញសម្តចព្រះវររាជបិតា នរោត្តម សីហនុ, សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន, ព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ និងសម្តេច ជា ស៊ីម" ("ញត្តិស្នើសុំ"), ៩ ឧសភា ២០១១, ERN 00686959-00686970 ។

[2] ញត្តិស្នើសុំ, ទំព័រទី១ ។

[3] ញត្តិស្នើសុំ, ទំព័រទី១ ។

[4] ឯកសារលេខ E86, "សេចក្តីសម្រេចស្តីពីការកំណត់កាលបរិច្ឆេទសម្រាប់បើកសវនាការបឋម"របស់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១១ ឧសភា ២០១១, ERN 00687015-00687016 ។

មហាក្សត្រ (RPA)[5] និងដីកាសម្រេចទី២ ទាក់ទងទៅនឹងគោលការណ៍ស្តីពីការជំនុំជម្រះក្តីពីរដងលើបទល្មើសដដែល (ne bis in idem)[6] ។ នៅក្នុងដីកាសម្រេចទាំងពីរនេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ក្រុមមេធាវីការពារក្តីត្រូវបានអនុញ្ញាតឲ្យដាក់អញ្ញត្រកម្មបឋមបន្ថែម ក៏ប៉ុន្តែបានកំរិតកំណត់លទ្ធភាពនេះចំពោះដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ដែលប្រឆាំងនឹងដីកាដំណោះស្រាយ[7]។

## III. ឧឡារិករណ៍

៣. ដោយ អង្គជំនុំជម្រះសាលាដំបូង បានចេញដីកាសម្រេចកំណត់កាលបរិច្ឆេទរបស់ខ្លួន ពីរថ្ងៃក្រោយញត្តិនេះ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូង តាមខ្លឹមសារនៃដីកា បានធ្វើការពិនិត្យពិចារណាលើសំណើរួចហើយ និងបានបដិសេធចោលនូវសំណើរបស់មេធាវីរូបនេះដែលសុំឲ្យធ្វើការកោះហៅសាក្សីនានានៅក្នុងពេលធ្វើសវនាការបឋម។ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា ខ្លួននឹងមិនធ្វើសវនាការដើម្បីស្តាប់ការលើកឧឡារិករណ៍ដោយផ្ទាល់មាត់ណាផ្សេងទៀតក្រៅពីអ្វីដែលមានចែងនៅក្នុងដីកាសម្រេចឡើយ ដោយបញ្ហាផ្សេងៗទៀតត្រូវបាន "កំណត់សម្រេចយ៉ាងច្បាស់ដែលឲ្យលែងមានការសង្ស័យតទៅទៀត ដោយអង្គជំនុំជម្រះ នៅក្នុងអង្គប្រជុំរៀបចំសវនាការ", "នឹងមានការណែនាំជាបន្ថែមទៀត" ឬ"មួយក៏អាចត្រូវបានលើកឡើងដោយភាគីនានានៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងអម្លុងពេលសវនាការ បើសិនជា ឬមួយក៏នៅពេលណា ដែលមានការទាក់ទងនិងចាំបាច់"[8]។ អាស្រ័យហេតុនេះ បញ្ហាស្តីពីការកោះហៅសាក្សីនានានៅក្នុងពេលសវនាការបឋមដើម្បីកំណត់អំពីវិសាលភាពនៃ RPA គឺត្រូវបានពិនិត្យពិចារណា និងបានបដិសេធចោលរួចហើយនៅក្នុងដីកាកំណត់កាលបរិច្ឆេទរបស់អង្គជំនុំជម្រះសាលាដំបូង[9]។

៤. មេធាវីការពារក្តីថ្លែងថា ក្រោមវិធាន ៨៧.៤ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះអាចកោះហៅសាក្សីណាក៏បាន។ ខណៈដែលរឿងនេះជាការពិត, វិធាន៨០*ស្ទួន* នៃវិធានផ្ទៃក្នុង ដែលនិយាយពីសវនាការបឋម ចែងថា - ដោយទាក់ទងទៅនឹងសាក្សី និងអ្នកជំនាញ - គោលបំណងនៃសវនាការនេះគឺដើម្បីឲ្យអង្គជំនុំជម្រះពិចារណាអំពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញសក្តានុពលទាំងឡាយ

---

[5] ឯកសារលេខ E51/8, សំណើរបស់អង្គជំនុំជម្រះសាលាដំបូងដែលសុំ "ដាក់អញ្ញត្រកម្មបឋមបន្ថែម" (ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស), ចុះថ្ងៃទី១២ ឧសភា ២០១១, ERN 00687378 ។

[6] ឯកសារលេខ E51/9, សំណើរបស់អង្គជំនុំជម្រះសាលាដំបូងដែលសុំ "ដាក់អញ្ញត្រកម្មបឋមបន្ថែម" (ការជំនុំជម្រះក្តីពីរដងលើបទល្មើសតែមួយ), ចុះថ្ងៃទី១២ ឧសភា ២០១១, ERN 00687381 ។

[7] ឯកសារលេខ D427/1/30, "សាលដីកាសម្រេច លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកដំណោះស្រាយ" របស់អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី១១ មេសា ២០១១, ERN 00661785-00661994 ។

[8] សេចក្តីសំរេចស្តីពីការកំណត់កាលបរិច្ឆេទ ។

[9] សេចក្តីសំរេចស្តីពីការកំណត់កាលបរិច្ឆេទ ។

ដែលដាក់ជូនដោយភាគីនានា[10]។ ដោយហេតុនេះ គោលបំណងនៃសវនាការបឋម គឺដើម្បីធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់អំពីការកោះហៅសាក្សី និងអ្នកជំនាញ គឺតាមពិតទៅ មិនមែនដើម្បីស្តាប់ចម្លើយសាក្សីទាំងនោះក្នុងពេលជាមួយគ្នានោះទេ។ ការណ៍នេះត្រូវបានបញ្ជាក់បន្ថែមទៀតដោយការបង្កើតវិធានផ្ទៃក្នុងសម្រាប់ អវតក ទាំងមូល, ដោយឡែក "ផ្នែក ង. នីតិវិធីនៅអង្គជំនុំជម្រះសាលាដំបូង" ជាពិសេស វិធាន ៧៩ ដល់ ៩១ ។ ដោយការអានតាមធម្មតានូវវិធានទាំងនេះ វាជាការមួយច្បាស់លាស់ ដែលមិនត្រូវបានឲ្យសញ្ញឹងគិតថា ត្រូវធ្វើការកោះហៅសាក្សីនៅពេលសវនាការបឋមនេះទេ ឬនៅពេលណាមួយ នៅមុនពេលមានសវនាការលើអង្គសេចក្តីនោះក៏ទេដែរ

៥. ជាឧទាហរណ៍ វិធាន ៨៤.២ នៃវិធានផ្ទៃក្នុង ចែងថា សាក្សីត្រូវបានកោះហៅភ្លាម កាលណាកាលបរិច្ឆេទកំណត់សវនាការត្រូវបានសម្រេចរួចហើយ ដោយមានការជាប់ទាក់ទងទៅនឹងវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង ដែលគ្រាន់តែអាចត្រូវបានធ្វើនៅក្រោយពេលសវនាការបឋម កាលណាអង្គជំនុំជម្រះ "ត្រូវពិចារណាអំពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញសក្តានុពលដែលដាក់ជូនដោយភាគី ស្របតាមវិធានផ្ទៃក្នុងនេះ" និងកាលណាអង្គជំនុំជម្រះពិចារណាឃើញថា សាក្សី ឬអ្នកជំនាញណាមួយដែលត្រូវបានស្នើសុំនោះ នឹងនាំមកនូវដំណើរការល្អនៃការស្វែងរកយុត្តិធម៌[11] តែប៉ុណ្ណោះ ។ សហព្រះរាជអាជ្ញា ស្នើថា គឺមានតែនៅក្រោយពេលសវនាការនេះតែប៉ុណ្ណោះ ដែលវិធានផ្ទៃក្នុងបានសញ្ញឹងគិតថា អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការកំណត់ផ្តាច់ព្រ័តរបស់ខ្លួន អំពីថាតើសាក្សី ឬអ្នកជំនាញណាមួយ ដែលត្រូវកោះហៅ ។

## IV. ដំណោះស្រាយដែលស្នើឡើង

៦. ហេតុនេះ ដោយសារតែញត្តិស្នើសុំនេះត្រូវបានសម្រេចរួចហើយ តាមរយៈសេចក្តីសម្រេចស្តីពីការកំណត់កាលបរិច្ឆេទសំរាប់ការបើកសវនាការបឋមរបស់អង្គជំនុំជម្រះសាលាដំបូង ហើយទោះក្នុងករណីណាក៏ដោយ វិធានមិនបានរំពឹងទុកអំពីការកោះហៅសាក្សីនៅពេលសវនាការបឋមទេ ដូច្នេះញត្តិស្នើសុំនេះ គួរត្រូវបានបដិសេធចោល៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក William SMITH**<br>សហព្រះរាជអាជ្ញារង | | [signature] |

[10] វិធាន *៨០ស្ទួន.២* នៃវិធានផ្ទៃក្នុង ។

[11] វិធាន *៨០ស្ទួន.២* នៃវិធានផ្ទៃក្នុង ។